# អតីតព្រះរាជអាជ្ញា ណ្យូរឹមប៊ឺជ ធ្វើការឆ្លុះបញ្ចាំងពីសារសំខាន់នៃ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ដោយ ហេនរី ឃីង**

*ប្រែសម្រួលដោយ ទែន សុខស្រីនិត*

***សេចក្តីថ្លែងការណ៍របស់លោក ហេនរី ឃីង ស្តីពីសារសំខាន់នៃអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា***

ខ្ញុំបានបំរើការជាព្រះរាជអាជ្ញាសញ្ជាតិអាមេរិកឲ្យតុលាការយោធាអន្តរជាតិនៅឯ ណ្យូរឹមប៊ឺជ ក្រោយពីសង្រ្គាមលោកលើកទីពីរ ។ សព្វថ្ងៃនេះ ខ្ញុំជាសាស្រ្តាចារ្យប្រចាំនៅសកលវិទ្យាល័យរីសឺវ វេស្ទឺនខេស មហាវិទ្យាល័យច្បាប់នៅ ខ្លេវឡែន រដ្ឋអូហៃយ៉ូ ។ ខ្ញុំចង់ចែករំលែកទស្សនៈរបស់ខ្ញុំទាក់ទិននឹងបញ្ហាប្រវត្តិសាស្រ្តជាមួយនឹងអ្នកទាំងអស់គ្នា ដោយផ្តោតលើសារសំខាន់នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលា-ការកម្ពុជា ឬហៅកាត់ថា អ.វ.ត.ក ។

អ.វ.ត.ក គឺជាតុលាការឧក្រិដ្ឋកម្មកូនកាត់ថ្មីបំផុតមួយដែលអនុវត្តទៅតាមច្បាប់អន្តរជាតិ ។ អ.វ.ត.ក និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិផ្សេងទៀតដូចជា តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រ៉្វាន់ដា និងសម្រាប់អតីតយូហ្គោស្លាវី និងក្នុងចំណោមតុលាការផ្សេងទៀត សុទ្ធតែត្រូវបានបង្កើតឡើងក្រោយតុលាការឧក្រិដ្ឋកម្មអន្តរជាតិណ្យូរឹមប៊ឺជ ។ ក្រោយពីសង្រ្គាមលោកលើកទីពីរ សហព័ន្ធរូស៊ីបានប្រឆាំងនឹងការទាមទារឲ្យមានការកាត់ទោសលើមេដឹកនាំជាន់ខ្ពស់ណាហ្ស៊ី ។ ដោយឡែកមេដឹកនាំវិស័យសេដ្ឋកិច្ច យោធា និងមេដឹកនាំនយោបាយ ត្រូវបានអនុញ្ញាតឲ្យទទួលបាននូវការកាត់ទោសដោយយុត្តិធម៌នៅណ្យូរឹមប៊ឺជ ដែលជាទីក្រុងមានឈ្មោះល្បីល្បាញដោយសារច្បាប់ដែលអនុញ្ញាតឲ្យមានការសម្លាប់ជនជាតិជ្វីហ្វ ។ ប៉ុន្តែនៅចុងទស្សវត្សរ៍ទី៤០ បុគ្គលដែលមានទោសទាំងអស់ត្រូវបាននាំមកវិនិច្ឆ័យទោស ហើយព័ត៌មានលម្អិតទាក់ទិននឹងឧក្រិដ្ឋកម្មសាហាវយោរយៅរបស់ជនទាំងនេះ ត្រូវបានផ្សព្វផ្សាយនៅទូទាំងពិភពលោក ។ ចលនាសិទ្ធិមនុស្សអន្តរជាតិក៏ត្រូវបានដំណើរការទៅមុខចាប់តាំងពីពេលនោះមក ។

ខ្ញុំមានសំណាងណាស់ដែលបានចូលបម្រើជាព្រះរាជអាជ្ញានៅក្នុងតុលាការឧក្រិដ្ឋកម្មរបស់ណូរីមបឺជ ។ ខ្ញុំមានអាយុ២៦ឆ្នាំ ហើយទើបតែបញ្ចប់ការសិក្សាផ្នែកច្បាប់ ខណៈពេលដែលខ្ញុំបានមកដល់ទីក្រុងណូរីមបឺជ កាលពីខែមីនា ឆ្នាំ១៩៤៦ ស្របពេលដែលមានព្យុះភ្លៀងយ៉ាងខ្លាំងនៅទីនោះ ។ ខ្ញុំបានរៀបចំសំណុំរឿងប្រឆាំងនឹងមេដឹកនាំជាន់ខ្ពស់ណាហ្ស៊ី ដូចជាធ្មើបទសម្ភាសន៍លោក អែលប៊ឺត ស្ពែរ ដែលជាមេដឹកនាំទីបីរបស់ប្រទេសអាល្លឺម៉ង់ ហើយខ្ញុំបានខិតខំប្រឹងប្រែងសហការជាមួយនឹងក្រសួងយុត្តិធម៌របស់តុលាការកំពូល និងលោកព្រះរាជអាជ្ញា រ៉ូប៊ឺត ចេកសាន់ ដើម្បីបំពេញកិច្ចការដ៏សំខាន់បំផុតមួយដែលហៅថា «ប្រើប្រាស់អំណាចដោយយោងតាមហេតុផលត្រឹមត្រូវតាមផ្លូវច្បាប់» ។

នាពេលបច្ចុប្បន្ននេះ មនុស្សប្រុសស្រីទូទាំងពិភពលោកដែលរួមទាំងប្រជាជនកម្ពុជាផងនោះកំពុងតែបានមកដល់ទីក្រុងភ្នំពេញ ដើម្បីតស៊ូស្វែងរកភាពទទួលខុសត្រូវ និងតស៊ូប្រឆាំងនឹងនិទ្ទណ្ឌភាព ។ ការនាំជនដែលមានការទទួលខុសត្រូវខ្ពស់ចំពោះឧក្រិដ្ឋកម្មសាហាវព្រៃផ្សៃរបស់ខ្មែរក្រហម ដើម្បីស្វែងរកយុត្តិធម៌តាមរយៈការកាត់ទោសដោយយុត្តិធម៌ និងបើកចំហរអាចជួយឲ្យ អ.វ.ត.ក មេធាវីជាតិ និងអន្តរជាតិ និងអ្នកគាំទ្រទាំងអស់រារាំងកុំឲ្យព្រឹត្តិការណ៍បែបនេះកើតឡើងម្តងទៀតនៅពេលអនាគត ។

ដូចគ្នានឹងតុលាការកាត់ទោសនៅណូរីមបឺជ ដំណើរការនីតិវិធីរបស់ អ.វ.ត.ក នឹងឆ្លុះបង្ហាញឲ្យឃើញនូវរចនាសម្ព័ន្ធរាជរដ្ឋាភិបាលរបស់កម្ពុជាប្រជាធិបតេយ្យ ឆន្ទះមេដឹកនាំនៃរបបនេះ និងពីវិធីសាស្រ្តដែលមេដឹកនាំទាំងនេះបានប្រើដើម្បីសម្លាប់មនុស្ស ការធ្វើទារុណកម្ម និងការប្រព្រឹត្តអំពើសាហាវឃោរឃៅផ្សេងៗទៀតដែលមានលក្ខណៈទ្រង់ទ្រាយធំ កាលពីចុងឆ្នាំ១៩៧០ ។ ដូច្នេះ អ.វ.ត.ក នឹងផ្តល់ជាការវិភាគវែកញែកពីព្រឹត្តិការណ៍ដែលបានកើតឡើងនៅក្នុងប្រទេសផ្តាច់ការនេះ ។ ជាមួយគ្នានេះ អ.វ.ត.ក នឹងផ្តល់ជាមេរៀនដល់ប្រជាជនខ្មែរ និងអ្នកគ្រប់គ្នាពីកាលៈទេសៈ ដែលបណ្តាលឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មបែបនេះ ។ សំខាន់ជាងនេះ អ.វ.ត.ក នឹងបង្ហាញថាតើយើងអាចបំបែកវដ្តព្រឹត្តិការណ៍ដែលនាំឲ្យមានជាការសម្លាប់ជាលក្ខណៈទ្រង់ទ្រាយធំបាននៅទីណា និងដោយរបៀបណា ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងជួយពង្រឹង និងផ្តល់សិទ្ធិអំណាចដល់ញត្តិនីតិរដ្ឋអន្តរជាតិដែលត្រូវបានវិវត្តន៍ និងអនុវត្តនៅណូរីមបឺជ ។ ទោះបីជារយៈពេលសាមសិបឆ្នាំបានកន្លងផុតទៅក៏ដោយយុត្តិធម៌អាចនឹងនៅតែកើតមានជានិច្ច ។ ក្នុងនាមជាប្រទេសដែលទើបតែនឹងចាកផុតពីរបបដ៏ឃោរឃៅរបស់ខ្មែរក្រហម ការនាំយកមេដឹកនាំខ្មែរក្រហមដែលនៅរស់រានមានជីវិត និងដែលមានការ

ទទួលខុសត្រូវលើឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តកាលពីអតីតកាលទៅវិនិច្ឆ័យទោសនឹងជួយធ្វើឲ្យមានការផ្សះផ្សារ ហើយនឹងជួយបង្កើតជាវិធានការដោះស្រាយបញ្ហាដែលអាចជួយឲ្យជនរងគ្រោះ និងក្រុមគ្រួសាររបស់គេមានភាពធូរស្បើយ ។

សំខាន់ជាងនេះ ដោយនាំយកមេដឹកនាំខ្មែរក្រហមមកទទួលខុសត្រូវចំពោះមុខច្បាប់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នឹងជួយរារាំងកុំឲ្យមេដឹកនាំនយោបាយដែលមានគោលនយោបាយប្រហាក់ប្រហែលគ្នានឹងខ្មែរក្រហមដើរតាមគន្លងចាស់របស់ខ្មែរក្រហម ។ តាមពិត ឆន្ទះបំរើការងារនៅឯតុលាការអន្តរជាតិណ្យូរិមបឺជរបស់ខ្ញុំ បានកើតចេញពីពាក្យសម្តីរបស់ឪពុកខ្ញុំ ។ កាលពីល្ងាចថ្ងៃអាទិត្យ ឆ្នាំ ១៩៣៥ ខ្ញុំបានសន្ទនាជាមួយឪពុករបស់ខ្ញុំ ។ គាត់បានសួរខ្ញុំថា «តើកូនអាចបញ្ឈប់សង្គ្រាមដោយរបៀបណា»? ខ្ញុំនឹកមិនឃើញថាត្រូវឆ្លើយនឹងសំណួររបស់គាត់ដោយរបៀបណាទេ ។ ក្នុងនាមជាអភិបាលក្រុងខនេកធីខ្យូត របស់ប្រទេសញូវអ៊ីងឡែន ក្នុងសម័យសង្គ្រាមលោកលើកទីមួយ ឪពុករបស់ខ្ញុំបានយល់ដឹងពីឥទ្ធិពលបំផ្លិចបំផ្លាញរបស់សង្គ្រាម ដែលមានមកលើយុវជនស្នងឫស្សីរបស់ជាតិ ។ គាត់បានប្រាប់ខ្ញុំថា«ប្រជាជនមិនចង់ឃើញសង្គ្រាមទេ ។ ប៉ុន្តែមេដឹកនាំចង់ឲ្យមានសង្គ្រាម ។ ដូច្នេះដើម្បីបញ្ឈប់សង្គ្រាម កូនត្រូវតែដាក់ទណ្ឌកម្មមេដឹកនាំទាំងនោះ» ។

ដូចគ្នានឹងតុលាការកូនកាត់ទូទាំងពិភពលោក អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងដើរតួជាអ្នកក្រើនរំឭកមេដឹកនាំដែលជឿថា ការប្រព្រឹត្តអំពើសាហាវឃោរឃៅគឺជារឿងត្រឹមត្រូវទាំងនោះថា ពួកគេនឹងមិនប្រឈមមុខនឹងគ្រោះថ្នាក់អ្វីទេពីព្រោះថា មេដឹកនាំទាំងនេះនឹងត្រូវបានផ្តន្ទាទោសដោយប្រជាជនរបស់ខ្លួន និងដោយសហគមន៍អន្តរជាតិ ទោះបីជាឧក្រិដ្ឋកម្មរបស់ពួកគេបានកន្លងផុតទៅអស់រយៈជាច្រើនទសវត្សរ៍ក៏ដោយ ។ ជាបន្តបន្ទាប់ យើងនឹងបង្ហាញឲ្យឃើញយ៉ាងច្បាស់ពីទស្សនៈដែលថាការទទួលខុសត្រូវចំពោះមុខច្បាប់មិនមានប្រសិទ្ធភាព នៅពេលដែលអំណាចមានឥទ្ធិពលខ្លាំងនោះថាមិនមែនជាការពិតទេ ។

ខ្ញុំសូមសង្ខេបបញ្ចប់ដោយសេចក្តីក្រើនរំឭកមួយថា សារសំខាន់នៃការកាត់ទោសប្រកបដោយយុត្តិធម៌ និងបើកចំហរមិនអាចមានការនិយាយបំផ្លើសបានឡើយ ។ ជោគជ័យសម្ងាត់របស់តុលាការកាត់ទោសណ្យូរិមបឺជ គឺពឹងផ្អែកយ៉ាងសំខាន់ទៅលើការគោរពយ៉ាងខ្ជាប់ខ្ជួនតាមនីតិវិធីរបស់តុលាការនេះ ។ ឧក្រិដ្ឋជនដែលបំរើឲ្យរបបណាហ្ស៊ី ត្រូវបានសន្មត់ថាគ្មានទោស ។ លើសពីនេះ ឧក្រិដ្ឋជនទាំងនេះ ទទួល

បាននូវមេធាវី និងឱកាសការពារខ្លួន ។ ដូចលោក ចាស៊ីក បេកសាន់ បាននិយាយក្នុងឱកាសថ្លែងសុន្ទរកថាជាលើកដំបូងរបស់លោកនៅតុលាការកាត់ទោសណ្យូរិមបឺដថា “ការផ្តល់ថ្នាំពុលមួយពែងដល់ជនជាប់ចោទ គឺដូចជាការដាក់ថ្នាំពុលចូលក្នុងមាត់របស់ពួកយើងទាំងអស់គ្នាដែរ” ។ (មានន័យថា ការកាត់ទោសដោយប្រហារជីវិតអាចផ្តល់ជាលទ្ធផលមិនល្អដល់យើងទាំងអស់គ្នា) ។ តុលាការនៅឯណ្យូរិមបឺដ ត្រូវបានចាត់ទុកថាមានលក្ខណៈត្រឹមត្រូវតាមផ្លូវច្បាប់ ហើយសូម្បីតែជនជាប់ចោទ និងមេធាវីរបស់ខ្លួនក៏យល់ដូច្នេះដែរ ។ ការតស៊ូប្រឆាំងនឹងការរំលោភសិទ្ធិមនុស្សមិនអាចសម្រេចបានទេ បើសិនជាយើងយកភ្លើងទល់នឹងភ្លើង ។ យើងត្រូវតែប្រកាន់ខ្ជាប់ខ្ជួនទៅនឹងបទដ្ឋានដែលយើងគ្រប់គ្រង ។ ហើយការប្រកាន់ខ្ជាប់ខ្ជួនទៅនឹងបទដ្ឋាន ក៏ត្រូវបានធ្វើឡើងនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរ ។

ជាចុងបញ្ចប់ ខ្ញុំសូមអបអរសាទរចំពោះការបង្កើតឲ្យមានគេហទំព័រឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហមដែលផ្តល់ជាសេវាកម្មផ្សព្វផ្សាយអង្គជំនុំជម្រះក្តីរបស់ អ.វ.ត.ក ដ៏មានប្រយោជន៍ដល់ពិភពលោក ។ ជាមួយគ្នានេះ ខ្សែវីឌីអូស្តីពីដំណើរការកាត់ទោសរបស់ ណ្យូរិមបឺដ ដែលបានបន្សល់ទុករហូតមកដល់សព្វថ្ងៃនេះ នឹងផ្តល់ជាកំណត់ហេតុប្រតិចារឹកស្តីពីដំណើរការនីតិវិធីរបស់តុលាការនេះសម្រាប់ជួយជាប្រយោជន៍ដល់តុលាការកាត់ទោសអន្តរជាតិជំនាន់ក្រោយឲ្យទទួលបានជោគជ័យ ។

មូលហេតុនេះហើយបានជាតុលាការកាត់ទោស ណ្យូរិមបឺដ មានកេរ្តិ៍ឈ្មោះរហូតមកដល់សព្វថ្ងៃនេះ ។ ខ្ញុំសង្ឃឹមថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នឹងជះឥទ្ធិពលប្រហាក់ប្រហែលគ្នានេះដល់ប្រទេសកម្ពុជា និងពិភពលោកទាំងមូល ដើម្បីជួយរារាំងកុំឲ្យមានការប្រព្រឹត្តអំពើសាហាវឃោរឃៅដោយធ្វើការរុះបញ្ចាំងឲ្យឃើញថាអ្នករំលោភច្បាប់នឹងត្រូវផ្តន្ទាទោស និងត្រូវទទួលខុសត្រូវចំពោះមុខប្រជាជនរបស់ខ្លួន និងសហគមន៍អន្តរជាតិ ។